

# ទៅលេងបុណ្យអុំទូក

All Children Reading - Cambodia

Seat Sopheap

letsreadasia.org



លីណា និង ដែន ឈរមើលគេ
ប្រណាំងទូកនៅមុខវាំង។



ក្រោយមក ពួកគេទាំងពីរនាក់ ដើរ
ប្រជ្រៀតគ្នាក្នុងហ្វូងមនុស្សជាច្រើន។



រំពេចនោះ ដែនវិលមុខ។



លីណា ក៏ឱ្យដៃនហិតប្រេងកូឡា។



បន្ទាប់មក ពួកគេនាំគ្នាទៅទិញនំចំណី
ញ៉ាំ ដើម្បីឱ្យមានកម្លាំង។



ស្រាប់តែពួកគេឮសូរ «ក្ដូង ក្ដូង... ក្ដូង!»។



លីណា និងដែនកាន់ដៃគ្នាយ៉ាងណែន។
ពួកគេភ័យញ័រទទ្រើក។



អូ! ភ្លើងកាំជ្រួច មានពណ៌ស្អាត
ណាស់។



ទៅលេងបុណ្យអុំទូក ការណែនាំ
បន្ថែមអំពីការប្រើប្រាស់សៀវភៅ
សៀវភៅរឿងនេះ បានផលិតឡើង
ដោយមានភ្ជាប់នូវសកម្មភាពនៅក្នុង
ទំព័រនីមួយៗ សម្រាប់ឱ្យសិស្ស
ធ្វើសកម្មភាពតាមសាច់រឿង។ នៅក្នុង
សកម្មភាពទាំងនោះមានប្រើនូវញាណ
ទាំ៥ និងចលនាផងដែរ។ លោកគ្រូ
អ្នកគ្រូអាចអានរឿង បន្ទាប់មកសិស្ស
ប្តូរវេនគ្នាដើម្បីធ្វើសកម្មភាព។ អត្ថបទ
រឿង - លីណា និង ដែន ឈរមើល គេ
ប្រណាំងទូកនៅមុខវាំង។ សកម្មភាព
- គ្រូឱ្យសិស្សកាន់ឈើ ឬខ្មៅដៃម្នាក់
មួយ ហើយធ្វើកាយវិការអុំទូកដោយធ្វើ



ចលនាដងខ្លួន ទៅមុខទៅក្រោយឱ្យស្របគ្នា សម្ភារៈដែលត្រូវប្រើ - ឈើវែង / ខ្មៅដៃ អត្ថបទរឿង - ក្រោយមកពួកគេទាំងពីរនាក់ ដើរប្រជ្រៀតគ្នាក្នុងហ្វូងមនុស្សជាច្រើន។ សកម្មភាព - គ្រូឱ្យសិស្សឈរក្បែរគ្នា ស្មាទល់ស្មា ហើយផ្អៀងទៅផ្អៀងមក (ដើរប្រជ្រៀតគ្នា) សម្ភារៈដែលត្រូវប្រើ - គ្មាន អត្ថបទរឿង - រំពេកនោះ ដែនវិលមុខ។ សកម្មភាព - គ្រូឱ្យសិស្សបង្វិលខ្លួនជុំវិញ សម្ភារៈដែលត្រូវប្រើ - គ្មាន អត្ថបទរឿង - លីណា ក៏ឱ្យដែនហិត ប្រេងកូឡា។ សកម្មភាព - គ្រូឱ្យសិស្សហិតប្រេងកូឡា សម្ភារៈដែលត្រូវ



ប្រើ - ប្រេងកូឡា ឬប្រេងខ្យល់ អត្ថបទ
រឿង - បន្ទាប់មក ពួកគេនាំគ្នាទៅ
ទិញ នំចំណីញ៉ាំ ដើម្បីឱ្យមានកម្លាំង។
សកម្មភាព - គ្រូឱ្យសិស្សភ្លក់នំផ្អែមៗ
ឬទឹកអំពៅ សម្ភារៈដែលត្រូវប្រើ - នំកង
នំអាកោរ ទឹកអំពៅ ឬនំ និងទឹកផ្សេង
ៗ អត្ថបទរឿង - ស្រាប់តែពួកគេឮសូរ
«ក្ទ្រូង ក្ទ្រូង... ក្ទ្រូង!»។ សកម្មភាព - គ្រូ
ឱ្យសិស្សស្តាប់សំឡេងបាញ់កាំជ្រួច
ដែលអាចរកបាននៅក្នុងអ៊ីនធឺណិត
/ ឬទះដៃឮទាំងគ្រូនិងសិស្ស សម្ភារៈ
ដែលត្រូវប្រើ - គ្មាន អត្ថបទរឿង - លី
ណា និងដែន កាន់ដៃគ្នាយ៉ាងណែន
ពួកគេភ័យញ័រទទ្រើក។ សកម្មភាព



- គ្រូឱ្យសិស្សកាន់ដៃគ្រូ ឬគ្រូកាន់ដៃសិស្សយ៉ាងតឹងណែន សម្ភារៈដែលត្រូវប្រើ - គ្មាន អត្ថបទរឿង - អូ! ភ្លើងកាំជ្រួច មានពណ៌ស្អាតណាស់។ សកម្មភាព - គ្រូឱ្យសិស្សមើលរូបថត ឬវីដេអូបាញ់កាំជ្រួច ឬបង្ហាញកាំជ្រួចធូប ឬដែកកេះ ឬបិទបើកភ្លើង សម្ភារៈដែលត្រូវប្រើ - កាំជ្រួចធូប គោលបំណងក្នុងការប្រើវិធីសាស្រ្តនេះ គឺដើម្បីឱ្យកុមារអាចចូលរួមស្តាប់ការនិទានរឿងទៅតាមកម្រិតសកម្មភាពផ្សេងៗគ្នារបស់ពួកគេ។ សិស្សខ្លះអាចចូលរួមពិភាក្សាអំពីគំនិតនៅក្នុងសាច់រឿង។ សិស្សខ្លះទៀតអានរៀន នូវ



ពាក្យថ្មីៗ និងរៀនពីការប្តូរវេនគ្នាម្តង់ម្នាក់ៗ។ ចំណែកឯសិស្សដទៃទៀតជាពិសេស កុមារខ្សោយសតិបញ្ញាធ្ងន់ធ្ងរ គឺដើម្បីឱ្យពួកគេចេះបង្ហាញទឹកមុខ ឬកាយវិការអំពីវត្ថុដែលពួកគេចូលចិត្ត ឬមិនចូលចិត្ត។ សៀវភៅនេះអាចធ្វើឱ្យសិស្សផ្សេងៗទៀត មានភាពសប្បាយរីករាយ និងមានអន្តរសកម្មភាពជាមួយគ្នា ក្នុងការស្តាប់រឿងនិទាន និងធ្វើឱ្យសិស្សទាំងនោះមានការចាប់អារម្មណ៍ជាមួយសៀវភៅ។



រឿងនិទាននេះបង្ហាញពីបងប្អូនពីរនាក់ ដែលនាំគ្នាទៅមើលការប្រណាំងទូក នៅក្នុងពិធីបុណ្យអុំទូក។ ពួកគេទាំងពីរនាក់ឃើញ ឮ ធុំក្លិន និងប៉ះពាល់វត្ថុផ្សេងៗគ្នាជាច្រើន។ យើងអាចប្រើសៀវភៅនេះសម្រាប់ មត្តេយ្យសិក្សា និងបឋមសិក្សា ឬអាចប្រើនៅផ្ទះក៏បាន។ យើងបង្កើតសៀវភៅនេះឡើង ដើម្បីឱ្យកុមារទាំងអស់អាចប្រើប្រាស់បាន រួមទាំងកុមារខ្សោយសតិបញ្ញាផងដែរ។ គោលបំណងក្នុងការបង្កើតសៀវភៅនេះឡើងគឺដើម្បីលើកកម្ពស់នូវការចូលរួម និងការសិក្សារបស់កុមារតាមរយៈការធ្វើសកម្មភាពសប្បាយៗ



នៅអំឡុងពេលនៃការស្តាប់ និងអាន
រឿងនិទាន។

អត្ថបទរឿងដោយ/ Text by All Children Reading-Cambodia (a USAID funded project supporting the Ministry of Education, Youth and Sport) and partners រូបគំនូរដោយ លោក សៀត សុភាព Illustration by Seat Sopheap រចនាទំព័រដោយ អង្គការស៊ីប៉ា Design by Sipar
This work is released under Creative Commons CC BY 4.0

Brought to you by

The Asia Foundation

Let’s Read! is an initiative of The Asia Foundation’s Books for Asia program that fosters young readers in Asia. booksforasia.org

To read more books like this and get further information about this book, visit letsreadasia.org

Original Story
ទៅលេងបុណ្យអុំទូក, author: All Children Reading - Cambodia . illustrator: by Seat Sopheap. Published by All Children Reading - Cambodia, © All Children Reading - Cambodia. Released under CC BY 4.0.

This work is a modified version of the original story. © The Asia Foundation, 2018. Some rights reserved. Released under CC BY 4.0.

For full terms of use and attribution, http://creativecommons.org/licenses/by/4.0/